**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**
**លេខ: [illegible] អអរ**

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## លទ្ធផលនៃដំណើរបំពេញទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋហ្វីលីពីន របស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់រាជរដ្ឋាភិបាល អញ្ជើញធ្វើមាតុភូមិនិវត្តន៍មកដល់រាជធានីភ្នំពេញ នាល្ងាចថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៥ នេះ បន្ទាប់ពីបានបំពេញទស្សនកិច្ចផ្លូវការរយៈពេល ២ថ្ងៃ ចាប់ពីថ្ងៃទី១០ ដល់ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៥ តបតាមការអញ្ជើញរបស់ ឯកឧត្តម **Ferdinand R. Marcos Jr.** ប្រធានាធិបតី នៃសាធារណរដ្ឋហ្វីលីពីន។ ដំណើរបំពេញទស្សនកិច្ចផ្លូវការនេះ បានផ្តល់សន្ទុះថ្មីក្នុងការពង្រឹងនិងពង្រីកបន្ថែមទៀតនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អដែលមានស្រាប់រវាងប្រទេសទាំងពីរ។

**ក្របខ័ណ្ឌនយោបាយ និងការទូត៖ សម្តេចធិបតី និងលោកជំទាវបណ្ឌិត** ត្រូវបានទទួលបដិសណ្ឋារកិច្ចផ្លូវការប្រកបដោយកិត្តិយស ភាពកក់ក្តៅ និងរាក់ទាក់ពីសំណាក់ ឯកឧត្តម **Ferdinand R. Marcos Jr.** ប្រធានាធិបតី នៃសាធារណរដ្ឋហ្វីលីពីន និងលោកជំទាវ នៅវិមានប្រធានាធិបតី (MALACANAN Palace) រដ្ឋធានីម៉ានីល មុនថ្នាក់ដឹកនាំកំពូលទាំងពីរបើកកិច្ចប្រជុំទ្វេភាគី។ ក្នុងជំនួបទ្វេភាគីនេះ ថ្នាក់ដឹកនាំទាំងពីរបានសម្តែងនូវការពេញចិត្ត និងវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អ និងចំណងមិត្តភាពដ៏យូរលង់រវាងប្រទេសទាំងពីរ។ ទន្ទឹមនឹងនោះ ថ្នាក់ដឹកនាំទាំងពីរក៏បានគូសបញ្ជាក់អំពីការបន្តជំរុញទំនាក់ទំនងទ្វេភាគីឱ្យឈានទៅដល់កម្រិតខ្ពស់ ក៏ដូចជាការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគីឱ្យកាន់តែរីកចម្រើន និងរឹងមាំបន្ថែមទៀត។ ថ្នាក់ដឹកនាំទាំងពីរក៏បានពិភាក្សាលើការលើកកម្ពស់ និងជំរុញកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌទ្វេភាគីលើវិស័យសំខាន់ៗជាច្រើនរួមមាន វិស័យពាណិជ្ជកម្ម វិនិយោគ ធុរកិច្ច ការពារជាតិនិងសន្តិសុខ កសិកម្ម សុខាភិបាល វប្បធម៌ អប់រំ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ បច្ចេកវិទ្យា និងការជំរុញការតភ្ជាប់ប្រជាជននិងប្រជាជននៃប្រទេសទាំងពីរ។ ថ្នាក់ដឹកនាំទាំងពីរក៏បានពិភាក្សាអំពីការពង្រឹងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរក្នុងក្របខ័ណ្ឌអាស៊ាន តំបន់ និងអន្តរជាតិផងដែរ។

ក្នុងឱកាសនោះ **សម្តេចធិបតី និងឯកឧត្តមប្រធានាធិបតី** បានអញ្ជើញជាអធិបតីក្នុងពិធីផ្លាស់ប្តូរឯកសារលើកិច្ចសហប្រតិបត្តិការចំនួន ០៨ រួមមាន ១. កិច្ចព្រមព្រៀងស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹង

ពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ ២. អនុស្សរណៈនៃការសម្តែងបំណង សម្រាប់កិច្ចសហប្រតិបត្តិការវិនិយោគរវាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងគណៈកម្មាធិការវិនិយោគហ្វីលីពីន ៣. អនុស្សរណៈនៃការយោគយល់គ្នាស្តីពីការបង្ការអំពើលួច និងជួញដូរខុសច្បាប់នៃទ្រព្យសម្បត្តិវប្បធម៌ ៤. អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើកសិកម្ម និងកសិ-ពាណិជ្ជកម្ម ៥. អនុស្សរណៈនៃការយោគយល់គ្នាស្តីពីការអនុវត្តច្បាប់ប្រកួតប្រជែង ៦. កម្មវិធីនៃការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការទេសចរណ៍ ៧. អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ៨. អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការនៅក្នុងវិស័យបច្ចេកវិទ្យាព័ត៌មាន និងបរិវត្តន៍កម្មរដ្ឋាភិបាលឌីជីថល។

នៅក្នុងឱកាសដ៏វិសេសវិសាលនេះ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានអញ្ជើញជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តម Ferdinand Martin Gomez Romualdez ប្រធានសភា នៃសាធារណរដ្ឋហ្វីលីពីន និងឯកឧត្តម Francis Joseph G. Escudero ប្រធានព្រឹទ្ធសភា នៃសាធារណរដ្ឋហ្វីលីពីន ដើម្បីបន្តពូនជ្រំចំណងទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធ រស់រវើក និងសកម្មរវាងស្ថាប័ននីតិប្បញ្ញត្តិនៃប្រទេសទាំងពីរឱ្យកាន់តែរឹងមាំបន្ថែមទៀត។

**ក្របខ័ណ្ឌសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគ៖ សម្តេចធិបតី** បានអញ្ជើញចូលរួមជាអធិបតីក្នុងវេទិកាធុរកិច្ចកម្ពុជា-ហ្វីលីពីន រៀបចំដោយសភាពាណិជ្ជកម្មកម្ពុជា ដែលមានវិនិយោគិនចូលរួមសរុបចំនួន ២០៩នាក់ មកពីបណ្តាក្រុមហ៊ុនចំនួន ១៥១។ នៅចំពោះមុខបណ្តាក្រុមហ៊ុនវិនិយោគហ្វីលីពីន **សម្តេចធិបតី** បានបង្ហាញពីសក្តានុពលវិនិយោគជាមួយនឹងការផ្តល់ជូនអត្ថប្រយោជន៍យ៉ាងច្រើនសម្បូរបែបរបស់កម្ពុជា ដែលផ្តល់នូវកាលានុវត្តភាពប្លែកពីគេ ព្រមទាំងអំណោយផលសម្រាប់ការបោះទុនវិនិយោគ។ **សម្តេចធិបតី** បានលើកឡើងថា កម្ពុជារក្សាបានកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧ភាគរយ ក្នុងមួយឆ្នាំ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច សន្ទុះនៃការវិនិយោគដោយផ្ទាល់ពីបរទេសបានកើនឡើង ១៥ដង ចន្លោះឆ្នាំ២០០៧-២០២២ ជាមួយនឹងភាពសម្បូរបែបនៃកម្លាំងពលកម្មវ័យក្មេង និងការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលកម្ពុជាស្ថិតនៅទីតាំងយុទ្ធសាស្ត្រចំកណ្តាលនៃអាស៊ាន ងាយស្រួលសម្រាប់ដឹកជញ្ជូន និងការតភ្ជាប់។ ជាពិសេស លទ្ធភាពក្នុងការចូលទីផ្សារតំបន់ និងសកលដ៏ទូលំទូលាយតាមរយៈកិច្ចព្រមព្រៀងនានា ដូចជាកិច្ចព្រមព្រៀងអាសិប កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយចិន កូរ៉េ និងអេមីរ៉ាត់អារ៉ាប់រួម ជាដើម។ **សម្តេចធិបតី** បានស្នើក្រុមហ៊ុនហ្វីលីពីននាំចូលអង្ករក្រអូបប្រណិតរបស់កម្ពុជាដោយផ្ទាល់ ដោយធ្វើការវិនិយោគទំនើបកម្មចង្វាក់តម្លៃអង្ករកម្ពុជា និងយុទ្ធសាស្ត្រទីផ្សារ ដើម្បីផ្សព្វផ្សាយអង្ករនៅទីផ្សារហ្វីលីពីន។

ក្នុងវេទិកាធុរកិច្ចនោះដែរ **សម្តេចធិបតី** បានបញ្ជាក់បន្ថែមថា កម្ពុជា-ហ្វីលីពីនកំពុងសហការគ្នាយ៉ាងសកម្មក្នុងការលើកកម្ពស់វិស័យទេសចរណ៍ និងសម្រួលដល់ភាពងាយស្រួលក្នុងការធ្វើដំណើររបស់ភ្ញៀវទេសចរ តាមរយៈការបន្តចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ ឆ្នាំ២០២៥-២០២៨។ ក្នុងន័យនេះ **សម្តេចធិបតី** បានស្នើឱ្យមានការតភ្ជាប់ជើងហោះហើរត្រង់ថ្មីបន្ថែមទៀតរវាងកម្ពុជា-ហ្វីលីពីន (សៀមរាប-សេប៊ូ) ជាពិសេសទៅកាន់គោលដៅទេសចរណ៍សំខាន់ៗរបស់កម្ពុជា ដើម្បីជំរុញកំណើនទេសចរណ៍

ទាំងតំបន់ទេសចរណ៍វប្បធម៌ និងតំបន់ទេសចរណ៍មាត់សមុទ្រ។ **សម្តេចធិបតី** បានស្វាគមន៍វិនិយោគិនពីគ្រប់ទិសទីទាំងអស់ មកឈ្វេងយល់អំពីកាលានុវត្តភាពដ៏សម្បូរបែបនៅក្នុងទីផ្សារដែលកំពុងរីកលូតលាស់យ៉ាងឆាប់រហ័ស ប្រកបដោយចីរភាព តាមរយៈយន្តការគាំទ្រ និងគន្លឹះដ៏គ្រប់ជ្រុងជ្រោយ ហើយរាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាសម្របសម្រួល និងធ្វើឱ្យការវិនិយោគទទួលបាននូវបទពិសោធដោយរលូននិងជោគជ័យ។

ក្នុងអំឡុងនៃវេទិកាធុរកិច្ចកម្ពុជា-ហ្វីលីពីននេះដែរ **សម្តេចធិបតី** ក៏បានផ្តល់កិត្តិយសអញ្ជើញជាអធិបតីក្នុងពិធីចុះអនុស្សរណៈនៃការយោគយល់គ្នាលើឯកសារចំនួន ០២ រួមមាន ១. អនុស្សរណៈនៃការយោគយល់គ្នារវាងសភាពាណិជ្ជកម្មកម្ពុជា និងសភាពាណិជ្ជកម្មនិងឧស្សាហកម្មហ្វីលីពីន ដើម្បីជំរុញកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ចរវាងប្រទេសទាំងពីរ ២. អនុស្សរណៈនៃការយោគយល់គ្នារវាងសាកលវិទ្យាល័យអាស៊ីអឺរ៉ុប និងសាកលវិទ្យាល័យ World Citi College ដើម្បីរួមគ្នាអភិវឌ្ឍវិស័យអប់រំ ជាពិសេសបង្កើតវគ្គបណ្តុះបណ្តាលលើជំនាញគិលានុបដ្ឋាយិកា។

ក្រៅពីវេទិកាធុរកិច្ចកម្ពុជា-ហ្វីលីពីន **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ក៏បានបន្តទាក់ទាញវិនិយោគិននានាក្រោមគោលការណ៍ **«រក្សាចាស់ បង្កើតថ្មី»** តាមរយៈជំនួបពិភាក្សាការងារផ្ទាល់ជាមួយក្រុមហ៊ុនឯកជនចំនួន ៣ រួមមាន ក្រុមហ៊ុន San Miguel Corporation, World Citi Group និង Exellent Associates Group Limited។ ក្រុមហ៊ុនទាំងនេះ មានប្រតិបត្តិការអាជីវកម្មលើវិស័យចំណីអាហារនិងភេសជ្ជៈ ការវេចខ្ចប់ រោងចក្រចម្រាញ់ប្រេង ថាមពល ហេដ្ឋារចនាសម្ព័ន្ធ អចលនទ្រព្យ អាកាសចរណ៍ អប់រំ ថែទាំសុខភាព បច្ចេកវិទ្យា សំណង់ ឧស្សាហកម្មរ៉ែ ការផលិតដែក សំណ និងស័ង្កសី ជាដើម។ ជាលទ្ធផល ក្រុមហ៊ុនទាំងនេះបានបង្ហាញចំណាប់អារម្មណ៍ពីសក្តានុពល និងស្វែងរកឱកាសវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធ អប់រំ និងសុខាភិបាលនៅកម្ពុជា។

នៅក្នុងឱកាសនៃដំណើរបំពេញទស្សនកិច្ចផ្លូវការនេះ **សម្តេចធិបតី** និង**លោកជំទាវបណ្ឌិត** បានអញ្ជើញទៅដាក់កម្រងផ្កានៅស្តូប RIZAL Park ដែលជាទីកន្លែងកំណើតនៃជាតិនិយមហ្វីលីពីន។ បន្ទាប់ពីនេះ **លោកជំទាវបណ្ឌិត** ក៏បានអញ្ជើញទស្សនាសារមន្ទីរ Centro de Turismo ដែលជាមជ្ឈមណ្ឌលទេសចរណ៍ និងសារមន្ទីរដែលមានតាំងពិព័រណ៍វត្ថុបុរាណប្រវត្តិសាស្ត្រ និងជាសម្បត្តិវប្បធម៌ដ៏មានតម្លៃពិសេស នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន។

គួរកត់សម្គាល់ថា នេះជាដំណើរទស្សនកិច្ចក្រៅប្រទេស **លើកទី១៨** និងជា**លើកទី៧** ក្នុងតំបន់អាស៊ានរបស់ **សម្តេចធិបតី ហ៊ុន ម៉ាណែត** ក្នុងនាមជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងក៏ជាដំណើរទស្សនកិច្ចក្រៅប្រទេសលើកដំបូងក្នុង ឆ្នាំ២០២៥។ ដំណើរបំពេញទស្សនកិច្ចផ្លូវការរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នៅសាធារណរដ្ឋហ្វីលីពីននាពេលនេះ គឺជាការបន្តបេសកកម្មការទូតដ៏សកម្មភ្លៀវក្លារបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ដើម្បីបង្កើតសមិទ្ធផលថ្មីៗបន្ថែមទៀត ទាំងផ្នែកការទូតនិងសេដ្ឋកិច្ចដើម្បីឧត្តមប្រយោជន៍ជាតិមាតុភូមិនិងប្រជាពលរដ្ឋ ជាពិសេសគឺការលើកស្ទួយកិត្យានុភាពជាតិកម្ពុជានៅលើឆាកតំបន់និងអន្តរជាតិ៕

ថ្ងៃអង្គារ ១៤កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៥